Khmer Story Lovers

ប្រលោមលោកប្រឌិតតាមសម័យបុរាណចិន

## ប្រលោមលោកចេញផ្សាយរៀងរាល់ថ្ងៃ



ចំណែកកាយជានរឹតតែស្រឡាំងកាំង ព្រោះកៅអីធ្វើពីគ្រឿងឈើមាំណាស់ បានន័យថា លោកនាយក្រុមខ្លាំងពូកែលើសដើម ។ ប្រហែលសំរេចវិជ្ជាវិសេសដែលគេនិយាយគ្រប់គ្នានោះហើយ ៗ នាងកែកាយផងភ័យក្តុកក្តួលផង និកថា:

– បើអ្នកប្រុសខ្លាំងពូកែយ៉ាងហ្នឹង បានអ្នកណាបង្ក្រាបគាត់ នៅពេលគាត់ប្រព្រឹត្តអំពើអាក្រក់ផ្សេងៗ ? ពិភពគុនច្បាស់ជាជ្រួលច្របល់ ដោយសារគាត់ទៀតហើយ !

អ្នកប្រែសម្រួល: អ.គីមសាន

តំម្លៃ

ផ្សាយចេញពីក្រុមអ្នកនិពន្ធ
«មាតុភូមិ»
ភ្នំពេញ

លេខ ៩

ពេលនោះមាណពសង្កាំងគិតបណ្តើរ ប្រយ៉ាច់កំទេចឈើថែមបណ្តើរ ម៉ង្គអស់រលីង ទើបពោលជួចមមើមមាយ :

– កៅអីធ្វើអំពីម្យ៉ាអីចឹងអង្គុយមើបកើត ?

ត្បិតកាលនៅតូច មាណពនេះមានសំណាងហាត់រៀនវិជ្ជាពិសម៉្យាងកាចសាហាវណាស់ ៗ វិជ្ជានេះមានលក្ខណៈពិសេសមួយ គ្រង់រៀនដល់អាយុម្ភៃឆ្នាំត្រូវស្លាប់បង់ជីវិត ក្នុងករណីដែលអ្នករៀនគ្មានថ្នាំលើកកម្លាំងពិសេសផឹកបន្សាបពិស បានសេចក្តីថាជនដែលបង្ហាត់បង្រៀននាយគ្មានបំណងល្អទេ ៗ

ថៃជន្សអីដល់បានមកជួបសៃយ៉ានទី គាត់ស់បង្ហាត់នាយឲ្យបំរើនធាតុក្តៅថែមលើហ្នឹងទៀត ព្រោះយល់ថា នាយជាសិស្ស

ទីងមិនហួសប្អូន ! បើគាត់ស្មានត្រូវមែន «កូនខ្លែងឥតពូជ» ច្បាស់ជាចេះវិធីបំរើនកម្លាំងទប់ទល់នឹងធាតុក្តៅខ្លះហើយ ។ អ្នកដែលបង្រៀនមាណពសុទ្ធតែប្រាថ្នាឲ្យនាយស្លាប់ដោយសារចំណេះផ្ទាល់ ។ ប៉ុន្តែព្រហ្មលិខិតបានដៅមកខុសពីបំណងមនុស្សលោក គឺមាណពមិនមែនសិស្សរបស់ទីងមិនហួសប្អូន, ហើយនៅពេលនាយត្រូវរងគ្រោះដោយកម្លាំងធាតុទាំងពីរធ្វើទុក្ខមែនទែន តៃហៃស៊ុ ទៅជួយទាន់ម្តងទៀត ។

ព្រោះហេតុអស់នេះហើយបានជាមាណពមិនស្លាប់ បែរជាសន្ធប់សន្ធិនទាំងថ្ងៃទាំងយប់ ។ តៃហៃស៊ីបានជួយនាយច្រើនណាស់ព្រោះស្មានថានាយជានាយក្រុមឈានហួ ។ បើគ្មានទេណា ទៅរកលោកនាយក្រុមស៊ីខាងក្រុមឈានល្អដល់កុំម៉ាន មាណពនេះត្រូវស្លាប់យ៉ាងគាណោចអធម កណ្តាលព្រៃឲ្យគ្មានគេដោះទៅហើយ ។

ពេលនេះទៀត នាយមិនត្រឹមតែរួចទុក្ខទោស, ថែមទាំងសម្រេចយុទ្ធសិល្បៈកំពូលដោយឥតដឹងខ្លួន ដោយសារចេនហៃទះមួយដៃក្តុតឈាមអាក្រក់អស់ពីកាយបណ្តាលឲ្យកម្លាំងធាតុទាំងពីរធ្វើចលនាស្មើគ្នាហើយរត់ត្របាញ់ចូលគ្នា យ៉ាងចំឡែកបានជាថាមពលម៉្យាងពូកែដ៏ចំណាន ។ មាណពឥតដឹងខ្យល់អីទេ ស្មានថាខ្លួនយល់សប្តិ , តែការពិតជាក់ស្តែងស្ថិតនៅត្រង់នាងគាយជានមានរូបរាងនិងសម្លេង . . .

នាយព្ញុតាយជានពោលតិចៗ:

- បើអ្នកប្រុសលើកលែងទោសឲ្យគាត់, ទុកជីវិតឲ្យគាត់ហើយ ម៉េចក៏ប្រដូចគាត់ទៅនឹង សត្តិរប្លាន! ម្តងនេះ គាត់ខឹងហើយស្អប់អ្នកប្រុសលើសដើមហើយ !

ពេលតែប៉ុណ្ណោះនាងដើរចេញពីបន្ទប់បាត់ មាណពនៅម្នាក់ឯងគ្រវីក្បាលគគាត់ពោលរអ៊ូ :

- ចំឡែកមែន ! ចំឡែកមែន !

នាយចោលភ្នែកទៅប៉ះប្រអប់ឈើទើបភ្ញាក់ស្មារតីថា : កូនតុក្កតានៅលើតុទេតើ ! មែនយល់សប្តិឯណាកើត ?

នាយបើកប្រអប់លើកតុក្កតាមួយមកពិនិត្យមើលស្រាប់តែព្រឺសរសៃព្រួកៗ បែកថ្នាំនិងកំទេចដីហុយប្រឡាក់ដៃពេញ ។ ត្បិតនាយមិនដឹងខ្លួនមានកម្លាំងលើសដើមហើយមិនចេះបន្ទរបន្ថយថាមពលទើបគ្រាន់តែចាប់កាន់មកលេងដូចធម្មតាក៏បែកដីអស់ ។

នាយលាន់មាត់ស្តាយកូនតុក្កតា ស្រាប់តែក្រឡេកឃើញសាច់ពណ៌ក្រហមច្រើន ១ លេចតាមស្នាមបែក នាយបេះដីចោលអស់ឃើញតុក្កតាដដែល ធ្វើពីឈើស្រាតខនលលោនស្រិល ទំនងជាមាននរណាដុះខាត់ដោយផ្ចិតផ្ចង់ណាស់ ។ ម្តងនេះតុក្កតាមានគំនូសខ្មៅពេញខ្លួន តែឥតមានចំណុចជីពចរសំខាន់ទេ , រីមុខមាត់ក៏ខុសមុនដែរ ។ រូបមួយនេះល្អមើលណាស់ គេឆ្លាក់ដូចមនុស្សមែនទែន ចាក់ក្តុកសើរើក គឺសើចស្ញាញយកដៃទាំងពីរទ្រក្បាលពោះ ។

មាណពអាយុម្ភៃឆ្នាំហើយតែនៅមានគំនិតក្មេង ចង់លេងតុក្កតាតទៅទៀតក៏ចាប់ម្តងមួយមកប្រដាប់ ជីងិនថ្នាំខាងក្រៅចោលអស់ព្រោះនាយចំណាំកន្លែងជីពចររបស់វាលីងហើយ ។ មែន! នៅក្រោមដីពណ៌ស សុទ្ធតែមានតុក្កតាឆ្លាក់ពីឈើលោនស្រិលសើរើកដូចគ្នាតែមានឫកពាខុសគ្នាទាំងអស់ ។ រូបមួយសើចសប្បាយ, មួយស្រែកហៅ, មួយយំសោកសង្រេង, មួយខឹងក្រេវក្រោធ, មួយទៀតធ្វើឫកអៀនខ្មាសដូចស្រីក្រមុំ.. រីសរសៃខ្មៅៗក៏ខុសប្លែកពីសរសៃឈាមលើសំបកមុនដែរ ។

មាណពនឹកថា :

-តុក្កតានេះល្អជាងមុន,គួរហាត់តាមវាម្តងមើល ! រូបនេះកុំហាត់តាមអីអាក្រក់មើលណាស់ យំស្ញ៉ប អ៊ីចឹង, រូបសើចនេះក៏មិនល្អមើលទៀតរយះមាត់ប្រវាបៗ ... នេះនៃ ! ធ្វើតាមរូបដែលមានឫកពាសុភាពរាបសាហើយញញឹមស្រួលបួលវិញ ។ នាយដាក់តុក្កតាពីមុខហើយប្រឹងដកដង្ហើមបន្តិច ស្រាប់តែកម្លាំងធាតុក្តៅនិរតែមកផ្តុំគ្នាភ្លាម ។ នាយបញ្ជូនកម្លាំងក្តៅនោះសន្សឹមៗតាមគំនូសលើរូបតុក្កតាឈើ ...

តុក្កតាទាំង ១៨ នេះជាប្រដាប់សំរាប់ហាត់រៀនវិជ្ជាកំពូលនៃអ្នកក្លាហានខាងក្រុមសៅលិនជី ឈ្មោះ « វិជ្ជាព្រះរូបបង្ក្រាបបិសាច » ជាវិជ្ជាផ្អែកលើកម្លាំងធាតុផ្អែកព្រះពុទ្ធសាសនាហើយតុក្កតានីមួយៗជាតំណាងព្រះមួយអង្គមានន័យទូលំទូលាយណាស់ មិនងាយអ្នកក្លាហានណាហាត់បេះទេ ។ មុនដំបូងត្រូវបេះប្រមូលអារម្មណ៍ និងចិត្តគំនិតជប្រះការខ្វាយខ្វល់ និងសៅហ្មងទាំងអស់ចេញសិន ទើបហាត់កើត ។ ចំណុចនេះឯងដែលគ្មាននរណាធ្វើបាន ព្រោះមនុស្សយើងកាលណាធ្លាកវង់វៃណាស់រឹតតែគិតច្រើនពិចារណាច្រើនណាស់ ម្ល៉ោះហើយមិនងាយនរណាមានចរិយាសម្បត្តិគ្រប់គ្រាន់បេះហាត់ស្ទៀតតាមកូនតុក្កតាទេ ។

មាណពនេះជាបុរសធ្លាកវង់វៃតែនាយមិនស្គាល់ធាតុជីវិតសោះឡើយ ព្រោះធ្លាប់រស់នៅព្រៃ

ក្នុងស្នាក់ជាមួយម្ដាយតាំងពីតូចមក ។ ចិត្តគំនិតនាយនៅល្អបរិសុទ្ធណាស់ឥតដែលស្គាល់ទុក្ខកង្វល់ទាល់តែសោះ ម្ល៉ោះហើយនាយអាចហាត់រៀនបានយ៉ាងជួរ ។ ពិសេសជាងហ្នឹងគឺនាយដឹងអាថ៌កំបាំងរូបតុក្កតាភ្លាម មុនពេលដើរតួនាយក្រុមឈានល្ង ។ បើពុំនោះសោត នាយពើបប្រទះព្រឹត្តការណ៍ប្លែកៗកើតក្ដីខ្វល់ខ្វាយអារម្មណ៍លែងមូលមិនខាន ។

អ្នកក្លាហានខាងក្រុមសៅលីងដឹងវៃឆ្លាតណាស់, គាត់ដឹងថាមនុស្សយើងលោភលន់ហួសហេតុចង់រៀនវិជ្ជាកំពូលនឹងអាចគ្រួតត្រាពិភពគុន ។ ដោយហេតុនេះបានជាគាត់យកដីឥដ្ឋនិងកំបោរធ្វើកូនតុក្កតា ហើយគូសសរសៃឈាមនិងចំណុចជីពចរឲ្យអ្នកគុននិយមទូទៅលែងចង់បាន ព្រោះសញ្ញាអស់នេះសាមញ្ញណាស់ ។ បំណងដ៏ធំរបស់គាត់គឺហាមឃាត់ក្មេងជំនាន់ក្រោយ មិនឲ្យហាត់រៀនតាមវិជ្ជាព្រះរូបបង្ក្រាបបិសាច ក្រែងបកជ័យស្លាប់អសារបង់ ។

តាពៃម្ចាស់កោះត្រីឆ្លាមដឹងល្អិតល្អន់ថាមានរូបតុក្កតាសំរាប់ហាត់រៀនវិជ្ជាដ៏វិសេសនេះ ទើបខំចំណាយពេលស្វែងរកអាថ៌កំបាំងនៃតុក្កតាទាំង១៨រាប់សិបឆ្នាំឥតបានទទួលលទ្ធផលសោះ ។ ប៉ុន្តែទោះបីយ៉ាងនេះក្ដីក៏តាពៃមិនប្រហែសឲ្យបាត់តុក្កតានេះដែរ, គាត់ជឿជាក់ថា ជាវត្ថុទិព្វវិសេសណាស់ម្ល៉ោះហើយគាត់ខំថ្នាក់ថ្នមដាក់ប្រអប់ទ្រាប់សំឡីមិនហ៊ានឲ្យរង្គើឡើយខ្លាចបាក់បែក ។

រូបតុក្កតា ១៨ ធ្លាក់ក្នុងដៃមាណពត្រឡប់ជាលេចរូបឈើខាងក្នុងប្លែកអស្ចារ្យទៅវិញ ។ តាពៃស្លាប់ហើយនៅ មិនទាន់ដឹងអាថ៌កំបាំងនៃតុក្កតាផង បានន័យថាមាណពមានសំណាងណាស់ ទើបធ្ងន់ដៃប្រចាប់តុក្កតាឲ្យរបេះចេញរូបពិត ។

តុក្កតាទាំង ១៨ នេះផ្លាស់ប្ដូរពីដៃមួយទៅដៃមួយគំរប់ដប់ពីរដងហើយ, ហើយម្នាក់ៗ ខំថែរក្សាមិនឲ្យបែកបាក់ប្រេះទេ , ទាល់តែស្លាប់ទៅវិញដូចតាពៃក៏មិនទាន់គេឃើញសាច់ឈើខាងក្នុងដែរ ។

មាណពមានកម្លាំងស្ដុកស្ដម្ភហាត់បញ្ចូលកម្លាំងតាមគំនូសខ្មៅលើរូបតុក្កតា បានបីដងក៏ធ្មេចភ្នែកលែងមើលគំរូហើយចំរើនកម្លាំងធាតុខ្លួនឯងម្ដង ។ នាយចាប់អារម្មណ៍ស្រួលក្នុងខ្លួនណាស់ ។ លុះចេះច្បាស់ហើយ នាយចាប់តុក្កតាមួយទៀតមកហាត់តាម, ប្ដូរពីមួយទៅមួយឥតចាប់ភ្លឹកនឹកនាដល់អ្វីៗ នៅជុំវិញខ្លួនឡើយ ។ មួយថ្ងៃហើយមួយយប់ទៀត ចេះតែហាត់មិនស្គាល់បាយទឹក ដូចល្បក់វង្វេងនឹងវិជ្ជាយុទ្ធសិល្បៈអ៊ីចឹង ។

នាងតាយជានឈរមើលទៅប្ដាយនាយ ដោយព្រួយបារម្ភ, តែហ៊ានសុំលបអើតមើលម្ដងៗ

ឃើញផ្សែងហុយពីក្បាលនាយក្រុម គាត់យល់ច្បាស់ថាហាត់រៀនបំរើនកម្លាំងដល់ដំណាក់ការសំខាន់តែហាមប្រាមគ្នា មិនឲ្យនាំទៅលោកនាយក្រុម ហើយឲ្យចាត់ការយាមល្បាតគ្រប់ច្រកល្ហក កុំឲ្យសត្រូវរំខាន ។

មាណពហាត់រៀនវិជ្ជាព្រះរូបបង្ក្រាបបិសាច តាមក្បួនគក្កតាំង ១៨ អស់បីយប់បីថ្ងៃទើបចប់ ហើយរៀបទុកដាក់ក្នុងប្រអប់វិញ ។ នាយឃើញប្លែកក្នុងខ្លួនតាំងពីលើកដៃលើកជើងទៅ, ភ្ញាក់សម្លឹងគ្រែដេកឃើញនាងតាយផានក្រាបដេកលក់ក្របៀនក្បែរនោះ ។ នាយក៏ឃើញនាងពាក់អាវស្តើង ក៏ទាញភួយដណ្ដប់ឲ្យយ៉ាងថ្នម ។ ត្បិតតាយផានឈរមើលអ្នកប្រុសហាត់រៀនពីរយប់បីថ្ងៃអត់ងងុយណាស់ទ្រាំមិនបានក៏លង់លក់ទាំងអង្គុយនាជើងគ្រែទៅ ។

ម៉ាណពដើរទៅឈរមាត់បង្អួច ដកដង្ហើមស្រូបក្លិនផ្កាក្រអូបឈ្ងប់មានកម្លាំងព្រឹសសប្បាយរីករាយណាស់ ស្រាប់តែឮតាយផានពោលតិចៗ នៅក្រោយខ្នង :

— អ្នកប្រុស . . . សូមអ្នកប្រុស . . . កុំសម្លាប់ខ្ញុំ ។

មាណពងាកមុខឆាំង:

— ម៉េចបងហៅខ្ញុំ "អ្នកប្រុស" ទៀតហើយ ? ម៉េចចេះតែអង្វរខ្ញុំមិនឲ្យសម្លាប់ ?

តាយផានដេកលក់មែន តែអារម្មណ៍នាងជិតជាប់លើនាយក្រុមកាចឃោរឃៅ នាងចេះតែភ័យបានជាវីវរវាយបែបហ្នឹង ។ គ្រាន់តែឮសូរសម្លេងមាណពភ្លាមនាងស្ទុះក្រោកភ្លេតយកដៃគក់ទ្រូង:

— ខ្ញុំខ្លាចណាស់លោកអើយ !

កាលបើមិនឃើញលោកនាយក្រុមសំកន្តលើគ្រែ នាងភ័យញ័រក្បាលមើលជុំទិសឃើញមាណពឈរមាត់បង្អួចទើបឧទាន :

— យី ! អ្នកប្រុសក្រោកហើយ ? ខ្ញុំ. .ខ្ញុំស្រាប់តែទន់ត្របកភ្នែក ...

នាងក្រោកឈររឹងរបូតភួយពីខ្លួនអស់ ក៏ភ័យស្លាំងមុខស្លូនថា ចៅហ្វាយនេះរំលោភលើរូបកាយនាងនៅពេលកំពុងលង់លក់ហើយដឹង ? នាងស្ទាបស្ទង់ខោអាវបន្តិច ឃើញនៅមានរបៀបដដែល ក៏បាត់ភ័យតែនាងសង្ស័យណាស់ ពោលទាំងញ័រញ័រថា :

— អ្នកប្រុស .. អ្នកប្រុស ... ខ្ញុំ ... ខ្ញុំ ..

មាណពសើច :

– អម្បាញ់មិញបងគាយអង្វរខ្ញុំមិនឲ្យសម្លាប់មនុស្សទៀតហើយ ។ បងយល់សប្តិឃើញខ្ញុំសម្លាប់គេឬ?

គាយផានអន់សង្ស័យនឹកក្នុងចិត្តថា ៖យើងយល់ប្រឡំទេដឹង? នាងឆ្លើយ:

–ចាស អម្បាញ់មិញខ្ញុំយល់សប្តិឃើញអ្នកប្រុសកាន់កាំបិតយ៉ាងស្អាត សម្លាប់មនុស្សគរលើគ្នា ហើយម្នាក់ៗសុទ្ធតែ... សុទ្ធតែ ...

នាងឈប់និយាយត្រឹមណោះ ព្រោះនាងស្រម័យឃើញគូនគក្កតា១៨លើតុលោកនាយ ក្រុមតាំងថ្ងៃតាំងយប់ហូតដេកលក់ទៅយល់សប្តិឃើញមាណពសម្លាប់មនុស្សគ្រប់ផុនស្រាតននល ។ នាងអៀនក្រហមមុខពោលលែងចេញ បណ្តាលឲ្យមាណពចង់ដឹង សួរសន្ទុញ:

– ម្នាក់ៗសុទ្ធតែយ៉ាងម៉េច?

គាយផានក្រហមដល់គុម្ពត្រចៀក:

– អ្នកប្រុសមិនមែនសម្លាប់សុទ្ធតែមនុស្សអាក្រក់ទេ ។

មាណពសើច:

– បងគាយអ៊្ហ! ខ្ញុំមិនយល់ការច្រើនណាស់, បងជួយប្រាប់ខ្ញុំផងបានទេ?

គាយផានញញឹមខ្ជឹប:

– លោកអើយ! ម្តេចក៏ឈឺម្តងប្រែចិត្តគំនិតអស់អ៊ីចឹង? ហៅបាវបំរើសុទ្ធតែបង!

- មកពីខ្ញុំមិនយល់ណា៎! ហេតុអីបងហៅខ្ញុំអ្នកប្រុស? ម៉េចបងជាអ្នកបំរើទៅវិញ? ហើយអស់លោកចាស់ទុំសុទ្ធតែហៅខ្ញុំថា«នាយក្រុម»ៗ ។ ចំណែកលោកបងត្រកូលចានដេរស្តីខ្ញុំថាល្បួចប្រពន្ធគាត់ ...រឿងហ្នឹងវាយ៉ាងម៉េច? ខ្ញុំមិនយល់ទេ ។

គាយផានសម្លឹងមាណពមួយសន្ទុះ ឃើញលេចចេញភាពស្មោះត្រង់មែន ក៏តបតាមធម្មតា:

– អ្នកប្រុសអត់បាយអត់ទឹកមួយយប់មួយថ្ងៃហើយ ខ្ញុំដាំឫសថ្នាំទុកជាស្រេច, ចាំខ្ញុំទៅដួសមួយចានមកជូន ។

មាណពត្រូវនាងរំឭកក៏ឃ្លានមួយរំពេច ពោលតប:

– មិនបាច់បងពិបាកទេ, បបរថ្នាំនោះនៅត្រង់ណា ខ្ញុំទៅដួសខ្លួនឯង ។

នាយដកដង្ហើមស្រង់ក្លិនរួចពោលបន្ត:

- ខ្ញុំស្គាល់ហើយ ។

នាយចាកចេញពីបន្ទប់ មកដល់ល្វែងមួយជាប់គ្នាឃើញបបរកំពុងពុះគ្រាក់ៗ លើជើងក្រាន ។ តាយជានដើរមកតាមក្រោយក្រហមមុខផាំង ពោលរអាក់រអួល :

- រីករហើយ បបរខ្ទាចអស់ ។

មាណពសើច :

- ខ្ទាចក៏ស៊ីបានដែរ . ខ្ទាចអីបង ?

ពេលចប់នាយអង្គុយចុះបើកគំរបឆ្នាំង ឃើញបបរខ្ទាចឡើងពណ៌ក្រហមពុំគួរគិនល្មៀមៗ ។ តាយជានពោល :

- សូមអ្នកប្រុសចាំពិសាចំណីផ្សេងវិញ, ខ្ញុំនាំជូនទៀត ។ ហ៊ឺ ! សិយអស្ចារ្យហើយ ! ដេកលក់ភ្លេចមើលបបរ ។

មាណពធ្លាប់រស់យ៉ាងកំសត់លើព្រៃភ្នំ គ្រាន់ត្រមោចឥតរើសអើងថា បបរខ្ទាច ឬបាយក្ដាំងទេ, នាយយកស្លាបព្រាដួសបបរគោកខ្ទាំងដាក់ក្នុងមាត់ផ្លុំ ! បបរនេះនាំជាមួយបុសថ្នាំ ប៉ុន្តែម្ចាំងល្វីងណាស់ ទាល់តែដាក់ស្ករសិនទើបទទួលទានបាន . ឥឡូវខ្ទាចទៀត មិនដឹងជាមានជាតិយ៉ាងណាទេ ។ មាណពលេបត្បៀតជ្រួញចិញ្ចើម លេបទឹកមាត់ផឹបៗ ហើយលៀនអណ្ដាត :

- ល្វីងណាស់ !

ពេលមួយម៉ាត់ដួសមួយស្លាបព្រាដាក់មាត់រួចថា ល្វីងណាស់ ។ តាយជានកញ្ឆក់ស្លាបព្រាពីដៃនាយហើយឃាត់ :

- បើខ្ទាចម៉្លឹងៗ ពិសាម្ដេចកើត ?

មាណពមិនព្រមលែងស្លាបព្រា តាយជានលូកប៉ះដៃនាយក្ដៅគគុក ហាក់មានកម្លាំងម៉្យាងចំឡែកចេញមកពេញណ្ដាញដៃនាងឲ្យខ្លាតឆ្ងាយ ។ នាងឈឺខ្លោកៗ ដកដៃយ៉ាងប្រញាប់, មាណពមិនដឹងអ្វីទេ ពឹតតែដួសបបរញ៉ាំទៅទៀត ។ តាយជានឈរសម្ងំមើលលោកនាយក្រុមហូបបបរធ្វើមុខជូរ កំអែសសំណើចខឹក :

- ដូចជាកំសត់ណាស់ហ្ន៎, ឥតអាហារប៉ុន្មានថ្ងៃឃ្លានដល់បន្ទុកតែម្ដង !

បបរនេះខ្ទាចមែន តែមានថ្នាំលើកកម្លាំងប៉ូវឈាមពូកែណាស់, បរិភោគរស់កាលណា

មាណពមានកម្លាំងព្រឺសកាណណាៈ ថែមទាំងមានទឹកមុខស្រស់ថ្លាប្លែកពីធម្មតាផង ។ តាយផាន សួរទាំងញញឹមៈ

- អ្នកប្រុសហាត់យុទ្ធសិល្បៈអ្វីហ្នឹង? គ្រាន់តែប៉ះបន្តិចខ្វាមកវិញតែម្តង, ឥឡូវទឹកមុខក្រហមល្អណាស់ ។

-ខ្ញុំមិនដឹងវិជ្ជាអីទេ គឺរៀនតាមរូបគគ្គាណា! បងតាយភ្លាំ! ប្រាប់មកមើល, ខ្ញុំជានណា?

តាយផានសើចៈ

- អ្នកប្រុសនឹកមិនឃើញមែន ឬ និយាយលេង?

មាណពលើកដៃអេះក្បាលៈ

- បងតាយបានជួបម៉ែខ្ញុំទេ?

តាយផានឆ្ងល់ណាស់ តបថាៈ

- ខ្ញុំជួបជាមិនដែលឮថា អ្នកប្រុសមានម្តាយទេ, អូ....ប្រហែលជាអ្នកប្រុសគោរពកោតខ្លាចអ៊ំស្រីណាស់បានជាប្រែចិត្តគំនិតដូច្នេះឬ?

- ហ្នឹងហើយ, យើងជាកូនត្រូវតែស្តាប់បង្គាប់ម្តាយ ។

នាយដកដង្ហើមធំពោលបន្តៈ

- តែគួរឲ្យស្តាយណាស់ ម៉ែខ្ញុំមិនដឹងទៅដល់ណាទេ!

- អូ សាធុទៅលោកអើយ! ក្នុងលោកនេះមានមនុស្សម្នាក់ដែលអ្នកប្រុសស្តាប់បង្គាប់ដែរ! ខ្ញុំត្រេកអរណាស់!

ពេលនោះឮសម្លេងខ្លាំងៗពីក្រៅ :

- លោកនាយក្រុមក្រោកហើយឬ ខ្ញុំបាទមានការមួយចង់ជំរាប!

មាណពភ្ញាក់ព្រើតបើកភ្នែកស្ញឹ,សួរតាយផានតិចៗថា គេនិយាយរកខ្ញុំឬ?

- ពាសមែនហើយ! គាត់ចង់ជួបអ្នកប្រុសនិយាយការ ។

មាណពភ័យអន្ទះអន្ទែងសួរយ៉ាងប្រញាប់ :

- បងឲ្យគេចាំបន្តិចសិនទៅហើយនែ... បងតាយ, ជួយបង្គាប់ខ្ញុំផងត្រូវធ្វើម៉េចខ្លះ?

តាយផានសម្ងំមុខនាយ ស្រែកតបវិញ :

- អ្នកណានៅខាងក្រៅ?

- ខ្ញុំបាទឈិនឈុងជី នាយត្រួតខាងសិល្បកំណាព !

- លោកនាយក្រុមបញ្ជាឲ្យនាយត្រួតរង់ចាំមួយភ្លែត ។

ឈិនឈុងជីឆ្លើយពីក្រៅថាបាទ ! មាណពនាំតាយផានចូលបន្ទប់ធំវិញសួរតិចៗ :

- ខ្ញុំជានរណាទៅបងតាយ ?

តាយផានបងចិញ្ចឹមដូចជាពិបាកចិត្តណាស់:

- អ្នកប្រុសជានាយក្រុមឈានល្អមានត្រកូលស៊ីឈ្មោះផាន ។

មាណពខ្ទេញ :

-ស៊ីផាន . . . ស៊ីផាន . . . ខ្ញុំមិនមែនឈ្មោះ ថ្កុតតូចទេឬ !

តាយផានឃើញនាយក្រុមមានកង្វល់ ក៏ពោលលួងលោម:

- សូមអ្នកប្រុសកុំខ្វាយខ្វល់ពេក, យូរៗទៅគង់នឹកឃើញរឿងចាស់ទាំងអស់ទេ ។

មាណពសួរទៀត:

- ក្រុមឈានល្អជាអ្វី ! នាយក្រុមគេត្រូវធ្វើអ្វីខ្លះ ? តាយផាននឹកថាបើពន្យល់ពីក្រុម ឈានល្អមិនងាយចប់ទេ ។ នាងសញ្ជឹងគិតបន្តិចទើបឆ្លើយ:

- ក្រុមឈានល្អនេះមានមនុស្សច្រើនណាស់ ដូចជាលោកគ្រូពេទ្យ និងនាយត្រួតឈិនដែលឈរចាំខាងក្រៅជាដើម ។ អ្នកអស់នោះសុទ្ធតែមានយុទ្ធសិល្បៈខ្ពង់ខ្ពស់, អ្នកប្រុសជានាយក្រុមត្រូវត្រួតគេទាំងអស់ បង្គាប់បញ្ជាអ្នកណាក៏បានដែរ ។

មាណពដែលគេឲ្យឈ្មោះថាស៊ីផានងក់ក្បាលមួយៗ រួចសួរទៀត :

- បងតាយឲ្យខ្ញុំទៅនិយាយជាមួយគេថាម៉េចខ្លះ ?

- ហ៊ឺ ! ខ្ញុំជាស្រីបំរើគ្មានដឹងកិច្ចការអីទេ ។ បើអ្នកប្រុសមិនដឹងសម្រេចរឿងអ្វីមួយសូមសួរលោកគ្រូពេទ្យ ព្រោះគាត់ជាទីប្រឹក្សា ឬអ្នកជំនាញការប្រចាំក្រុម, គាត់ឆ្លាតវាងវៃណាស់ ។

- ចុះបើលោកគ្រូពេទ្យឥតនៅជិតខ្ញុំផង ធ្វើម៉េចទៅ ? នែបងតាយ, បងដឹងថាលោកនាយនោះចង់និយាយរឿងអ្វីដែរ ? បើគេសួរ ខ្ញុំឆ្លើយមិនរួចច្បាស់ជារវើរវាយហើយមែនទេ ? បងតាយក្អៀ...បងឲ្យគាត់ត្រឡប់ទៅវិញចុះ ។

- ប្រាប់គាត់ឲ្យត្រឡប់ទៅវិញដូចជាមិនស្រួលទេ ។ ណ្ហើយ ! អីចេះចុះ អ្នកប្រុសចេញទៅទទួល ស្តាប់គាត់និយាយសិន, បើមិនចេះធ្វើយ អ្នកប្រុសឆក់ក្បាលទៅការស្រេចហើយ ។

ស៊ីផានរីករាយណាស់ពោល:

- អីចឹងក៏ស្រួលម្យ៉ាងដែរ ។

តាយផានទាញនាយក្រុមចូលបន្ទប់តូចសម្រាប់ទទួលភ្ញៀវ ។ បុរសម្នាក់មាឌធំស្ទុះក្រោកពីកៅអី លំអោនកាយគោរព :

- ជំរាបសួរលោកនាយក្រុម ខ្ញុំបាទឈិនឈុនជី ។

ស៊ីផាន គោរពតបវិញ :

- លោក.. លោកនាយត្រួតសុខសប្បាយទេ ? ខ្ញុំសុំជំរាបសួរលោកដែរ ។

ឈិនឈុនជីស្រឡាំងកាំង ថយក្រោយពីរជំហានភ្លាម ព្រោះគាត់ធ្លាប់ស្គាល់លោកនាយក្រុមកាចសាហាវឃោរឃៅ ហើយបុកពាឆ្នើនឆ្នៃក្រៃលែង ។ បើលោកនាយគោរពតបវិញខុសពីធម្មតា មានតែចង់ដាក់ទោសដោយប្រការណាមួយ ។

ឈិនឈុនជីភ័យមែន តែកំណើតជាអ្នកក្លាហាន គាត់ខំទប់ចិត្តឲ្យនឹងនចំរើនកម្លាំងជាតុការពារជាស្រេច ទើបពោលមួយៗ :

- មិនដឹងខ្ញុំបាទមានប្រព្រឹត្តអីខុសទេ , បើលោកនាយក្រុមចង់ដាក់ទណ្ឌកម្ម សូមគោះប្រជុំសមាជិកទាំងអស់សិន ។

ស៊ីផានមិនយល់សំដីនាយត្រួតសោះ ក៏សួរទាំងភ្ញាក់ផ្អើល :

- ដាក់ទណ្ឌកម្ម ' ដាក់ទណ្ឌកម្មស្អី ? លោកនាយត្រួតឈិនមានប្រសាសន៍ថាដាក់ទណ្ឌកម្មស្អី ?

ឈិនឈុនជីខឹងក្រោធ ពោលថា :

- ឈិនឈុនជីខ្ញុំបាទមានចិត្តស្មោះត្រង់ចំពោះក្រុមនិងនាយក្រុមមិនដែលប្រព្រឹត្តល្មើសនឹងច្បាប់ទេ ហេតុអ្វីលោកនាយក្រុមពោលពាក្យចំអកដូច្នេះ ?

ស៊ីផាននឹកឃើញបណ្តាំតាយផានដែលប្រាប់ថា កាលណាស្តាប់សំដីនាយត្រួតមិនយល់ឲ្យឆក់ក្បាលទទួលបណ្តោះអាសន្នសិនទៅ ចាំសួរបញ្ជាក់ពៅហៃសុីជាក្រោយ ។ ហេតុនេះនាយ

ងក់ក្បាលអ៊ឺអើ តបថា :

- សូមលោកនាយត្រួតឈិនអង្គុយចុះមក ! កុំគួរសមពេក !

ឈិនឈុនជីតបទៅវិញ :

- នៅចំពោះមុខលោកនាយក្រុម ខ្ញុំបាទមិនហ៊ានអង្គុយទេ ។

ស៊ីផានងក់ក្បាលទៅស្ងៀប ។ អ្នកទាំងពីរឈរទល់មុខគ្នា មិនចេញស្តី ។ ឈិនឈុនជីភិតភ័យតក្កមា ឯស៊ីផានរវើរវាយនិងនឿងឆ្ងល់ក្រៃលែង តែនាយញញឹមយ៉ាងសុភាព ។ តាមទម្លាប់ក្រុមឈ៉ានលួ នៅពេលបានសេនាចូលជួបនាយក្រុមដើម្បីពិគ្រោះកិច្ចការផ្ទុកផ្ដង ៗ មិនអនុញ្ញាតឲ្យនរណានៅជិតទេ ដូច្នេះទើបគាយផានចៀសចេញឆ្ងាយតាំងពីដំបូងម៉្លេះ ។ ប្រសិនបើនាងនៅទីនេះច្បាស់ជាអាចជួយពន្យល់ឈិនឈុនជីថានាយក្រុមទើបនឹងជាសះស្បើយ ហើយចិត្តគំនិតមិនទាន់ភ្លឺស្វាងទេ នោះឈុនជីប្រាកដជាពុំហ្ន៎សៅសង្ស័យដល់ម៉្លឹងឡើយ ។

ស៊ីផានក្រឡេកឃើញទឹកតែពីពានលើតុ ក៏លូកដៃយកមួយពាន ហើយមួយពានទៀតហុចឲ្យឈុនជី ។ នាយត្រួតសង្ស័យខ្លាចក្រែងមានដាក់ថ្នាំពិស ហើយក្រែងផានធ្វេីតទុកាសវាយលុក ក៏មិនហ៊ានទទួលហើយថយក្រោយក្រាក ៗ បណ្តាលឲ្យពានតែធ្លាក់បែកប្រាវ !

ស៊ីផានលាន់មាត់ អូ ! ញញឹមពោលថា :

- សូមអត់ទោស !សូមអត់ទោស !

ពោលហើយនាយហុចពានតែរបស់ខ្លួនទៅឲ្យឈុនជី :

- សូមលោកពិសាមួយពាននេះចុះ !

ឈិនឈុនជីជ្រួញចិញ្ចើមទឹកថា « គង់តែមិនរួចពីក្រញាំដៃពិសរបស់ឯងដដែល យើងជាកូនប្រុសស្លាប់ក៏ស្លាប់ចុះ ចាំបាច់ព្រួយបារម្ភធ្វើអ្វី? » គិតហើយក៏ទទួលបានតែមកផឹកក្អឹកៗ អស់ក្អម ។ គាត់ពោលទាំងភ័យព្រួយ :

- បើលោកនាយក្រុមចិត្តល្អចំពោះសេនាដ៏ស្មោះត្រង់ដូច្នេះ សូមលោកមានអាយុយឺនយូរ !

ស៊ីផានយល់ពាក្យ « អាយុយឺនយូរ » ដែរ តែពុំបាប់ភ្ញាក់ថាឈុនជីប្រើពាក្យនេះក្នុងន័យផ្ទុយស្រឡះទេ ។ នាយតបដោយស្មោះសរ :

- ខ្ញុំក៏សូមឲ្យលោកនាយត្រួតឈិនមានអាយុវែងដែរ ។

តែឈុនជីបែរជាយល់ច្រឡំថា នាយចំអកឡកឡឺយយ៉ាងចាប់ជាក់ទៅវិញ ។ គាត់សើចហ៊ឹះ ! គិតថា « ជីវិតយើងនឹងសាបសូន្យនៅពេលបន្តិចទៀតខាងមុខនេះហើយ តែឯងបែរជាជូនពរឲ្យយើងអាយុវែងទៅវិញ » គិតរួចគាត់ពោលខ្លាំងៗ :

- មិនដឹងជាខ្ញុំបានធ្វើអ្វីឆ្គាំឆ្គងខ្វះចំពោះលោកនាយក្រុម ទើបទទួលវាសនាអាក្រក់ដូច្នេះ តែមិនហ៊ានតវ៉ាទេ គ្រាន់តែសូមជម្រាបថា កាលពីយប់មិញ ស្ត្រីពីរនាក់បានចូលមកទីចាត់ការក្រុមសិង្ហកំណាចខ្ញុំបាទ ម្នាក់អាយុប្រហែលសែសិប ម្នាក់ទៀតម្ភៃប្រាំពីរឬម្ភៃប្រាំបីឆ្នាំប៉ុណ្ណោះ ។ ស្ត្រីទាំងពីរប្រើដាវ ហើយមានស្នៀតប្រហាក់ប្រហែលពួកភ្នំទឹកកក ។ ខ្ញុំបាទនាំសេនាចេញប្រតិបត្តិការ នៅទីបំផុតស្ត្រីក្មេងត្រូវមួយកាំបិត ក៏ត្រូវពួកយើងចាប់បាន តែខាងយើងមានស្លាប់បីនាក់ សូមលោកនាយក្រុមជ្រាបជាដំណឹង !

ស៊ីផានស្តាប់ចប់ពោលថា:

- អូ ! ចាប់បានម្នាក់រត់រួចម្នាក់ ។ តើស្ត្រីទាំងពីរមកធ្វើអ្វីដែរ? មកលួចអ៊ីក៏ន?

- នៅក្នុងទីចាត់ការសិង្ហកំណាច ដូចជាគ្មានអ្វីគួរលួចទេ!

ផានជ្រួញចិញ្ចើម :

- ស្ត្រីទាំងពីរនេះកាចសាហាវណាស់តើ ! ម៉េចក៏សម្លាប់មនុស្សដល់ទៅបីនាក់អញ្ចឹង?

មិនទាន់អស់ចិត្ត, នាយពោលបន្ត :

- លោកនាយត្រួតឈិន ! សូមលោកនាំខ្ញុំទៅមើលមុខស្ត្រីនោះផងបានទេ ?

ឈិនឈុនជីលំអោនកាយតប:

- ទទួលបញ្ជា !

ហើយបែរក្រោយដើរនាំមុខ ស្រាប់តែផុសបានគំនិតមួយ « នារីដែលចាប់បាននោះស្រស់ស្អាតគ្រាន់បើដែរ ទោះអាយុច្រើនបន្តិចក៏ដោយ ប្រសិនបើលោកនាយក្រុមពេញចិត្ត ប្រហែលជាអញបានថ្នាំបន្សាបពិសមិនខាន ! »

ដល់ត្រង់ណេះក៏នឹកតទៅទៀត : « ឈិនឈុនជីអើយ ឈិនឈុនជី ! លោកនាយក្រុមមានចិត្តកាយមាយណាស់ សប្បាយរីកថ្លើមរីកប្រមាត់ ឬខឹងក្រេវក្រោធនេវនាវមិនទៀងទាត់ទេ ហើយមានបុគ្គលិកព្រហើនកោងកាច ប្រឡេសប្រើសទៀតផង ! ក្រុមឈានលួមិនមែនជាកន្លែងដែលឯង

អាចកសាងសុភមង្គលបានទេ ថ្ងៃក្រោយបើនៅមានជីវិតឯងតោងគេចចៀសវាងចេញឲ្យឆ្ងាយ បង្កប់ខ្លួនលាក់ឈ្មោះ កុំនៅរើរាមទីនេះទៀត !

ស៊ីផានដើរតាមក្រោយនាយត្រួតចេញផុតបន្ទប់ឆ្លងកាត់សួនច្បារពីរ ទើបដល់ទ្វារមួយយ៉ាងធំ , មានសេនាបួននាក់ឈរយាមសងខាងច្រកចូល ។ ពួកទាំងនោះស្ទុះមកធ្វើគារវកិច្ចយ៉ាងឱនលំទោន និងញញើតញញើមជ្រើមជ្រួលក្តួលក្តុកគួរក្រៃលែង ។ ឈុនជីលើកដៃ ទើបសេនាពីរនាក់ប្រញាប់ទៅបើកទ្វារថ្ម ។ ក្រោយទ្វារថ្ម មានទ្វារដែកមួយជាន់ទៀតចាក់សោយ៉ាងជាប់ ។ ឈិនឈុនជី ចូលបើកសោហើយដើរនាំមុខបន្តទៅទៀត ។ គឺជាផ្លូវមួយយ៉ាងវែង , នៅសងខាងមានអុជទៀនភ្លឺព្រោងព្រាត ហើយខាងមុខ,សេនាបួនរូបឈរយាមជិតទ្វារដែកមួយ ។

ផុតទ្វារដែកមានទ្វារថ្មមួយទៀតយ៉ាងក្រាស់ ហើយបន្ទាប់មកគឺជាបន្ទប់ថ្មប្រវែងបីម៉ែត្របួនជ្រុង ។ នារីម្នាក់ពាក់អាវស អង្គុយកៀនជញ្ជាំងបែរមុខសម្លឹងមកយ៉ាងអង់អាច ។ ក្រោមពន្លឺទៀន ស៊ីផានឃើញមុខនាងច្បាស់ ក៏លាន់មាត់អួ ! ហើយពោលថា :

- អ្នកនាងគឺនារីផ្កាកុលាបហ្លួវ៉ាន់ជីនៃក្រុមក្អំទឹកកកមែនទេ ?

កាលនៅភូមិហ្វូវផាន ហ្លួវ៉ាន់ជីបានប្រើពាក្យញុះញង់ទាល់តែសៀវយានទី រលាស់ដៃការធ្វើឲ្យដួល ហើយពេលនោះស៊ីផានពុំយល់គេឆ្លងឆ្លើយគ្នារឿងអ្វីទេ ឯពាក្យថាក្រុមក្អំទឹកកកនិងនារីផ្កាកុលាប ក៏នាយពុំដឹងមានន័យយ៉ាងដូចម្តេចដែរ តែដោយប្រសប់ចាំសំដីក៏បេះតែចាំរហូតមក ។ ពេលវេលាកន្លងទៅច្រើនឆ្នាំហើយ តែហ្លួវ៉ាន់ជីហាក់គ្មានផ្លាស់ប្តូរអ្វីច្រើនសោះ ទើបមាណពអាចមើលស្គាល់ ។ កាលនោះផានជាកូនស្ទាវប្រឡាក់ប្រឡូសសុទ្ធតែដី តែឥឡូវនាយជាយុវជនមួយរូបយ៉ាងស្រស់សង្ហា ធ្វើម៉េចហ្លួវ៉ាន់ជីអាចចំណាំបាន ?

នាងខឹងក្រេវក្រោធ សួរថា :

- ម៉េចឯងស្គាល់យើង ?

ឈិនឈុនជី ឃើញស៊ីផានមើលមុខនារីនេះបន្តិច អាចស្គាល់ឈ្មោះផងនិងក្រុមនាងភ្លាម ក៏ស្ងើចសរសើរក្រៃលែង ហើយនឹកក្នុងចិត្តថា « លោកនាយក្រុមពិតជាមានភ្នែកមុតប្លែកពីមនុស្សធម្មតាមែន» ។ គាត់ស្រែកគំហក :

- នេះជាលោកនាយក្រុមរបស់យើង នាងឯងឲ្យចេះនិយាយគួរសមខ្លះផង !

សិស្សភ្ញុំទឹកកកក្រាក់ព្រើត ព្រោះមិនស្មានថា បានជួបនាយក្រុមឈានល្បីមានឈ្មោះស្អុយគគ្រុក នៅក្នុងទីឃុំឃាំងដូច្នេះសោះ ។ នាងធ្លាប់ឮរឿងថា ស៊ីផធានជាមនុស្សល្មោភកាមតណ្ហា ធ្លាប់បានបំផ្លាញសេចក្ដីបរិសុទ្ធរបស់នារីជាច្រើន ។ នាងព្រួយបារម្ភណាស់ ព្រោះថ្ងៃនេះធ្លាក់ក្នុងកណ្ដាប់ដៃព្រាននារីច្បាស់ជាកុនខ្លួនហើយ ។ នាងម្ហីម្ហាំងាកមុខមករកជញ្ជាំងដើម្បីកុំឲ្យគេគយគន់សម្រស់ខ្លួនទៀត ។ កាយវិការនេះធ្វើឲ្យច្រវាក់ដែលជាប់នឹងដៃជើងលាន់ព៉ើកព៉ើកក្ខាម ។

ស៊ីផធានមិនដែលឃើញច្រវាក់សម្រាប់ចងជើងដៃទេ ធ្លាប់តែឮក្នុងរឿងនិទានដែលម្ដាយនិយាយឲ្យស្ដាប់ ។ ហេតុពេលនេះ នាយទើបនឹងបានឃើញផ្ទាល់ភ្នែកម្ដង ។ នាយសួរសហការី:

- លោកនាយត្រួតឈិន! អ្នកនាងហ្នឹងមានទោសពៃរ៍អ្វីដែរ ទើបជាប់ច្រវាក់ដៃជើងដូច្នេះ ?

នាយសួរក្នុងន័យស្លោះត្រង់សោះ តែឈុនជីយល់ខុសស្រឡះហើយនឹកថា "លោកនាយក្រុមខឹងនឹងអញ ធ្វើបាបនាងនេះឲ្យផឹកថ្នាំពិស ដូច្នេះគាត់ងាប់រកមធ្យោបាយរំដោះខ្លួនសិនទើបប្រសើរ ។ កើតមកជាកូនប្រុសដើមទ្រូងប្រាំហត្ថ មិនត្រូវស្លាប់ដោយសារស្រីទេ!" គាត់ប្រញាប់លំទូនកាយ:

- បាទ! បាទ! ខ្ញុំបាទដឹងខ្លួនខុសហើយ!

គាត់លូកយកកូនសោតាក់ខ្នោះចេញពីដៃជើងហ្លួវាន់ជីក្វាម ។ នាងក្រមុំមានសេរីភាពកាលណា កាន់តែភ័យញ័រកាលណោះ នាងគិត "យើងសុខចិត្តរស់ក្នុងទីឃុំឃាំង ដែលគ្មានពន្លឺព្រះអាទិត្យអស់មួយជីវិតជាជាងព្រមទៅជួបឯងក្នុងបន្ទប់" ។

នារីផ្កាកុលាបហ្លួវាន់ជីមានរាង្គខ្ពង់ខ្ពស់ល្អសម ប្រាជ្ញាវាងវៃនិងក្លាហានអង់អាចកម្ររកបានណាស់ ប្រសិនបើស៊ីផធានគម្រាមកំហែងចង់សម្លាប់ នាងមិនព្រឺខ្លាចទេហើយថែមទាំងហ៊ានតវ៉ាប៉ប៉ាច់ប៉ប៉ោច យ៉ាងក្លៀវក្លាផង ។ តែនេះបែរជាឮស៊ីផធានបន្ទោសឈុនជីទៅវិញ គឺហាក់ដូចជាចង់ផ្គាប់ផ្គុននាងក្នុងបំណងដ៏ថោកទាបណាមួយ ។ មួយជីវិតនេះនាងបានរក្សាសេចក្ដីបរិសុទ្ធរហូតមក លុះនឹកដល់កេរ្តិ៍ឈ្មោះអសោចរបស់នាយក្រុមស៊ី ក៏ព្រឺក្បាលសំពោង ។ ឈិនឈុនជីយកចិត្តយកថ្លើមទៅហៅនាយ:

- លោកនាយក្រុមគួរតែអញ្ជើញអ្នកនាងហ្នឹងទៅបន្ទប់ទៅ ទីនេះងងឹតហើយគ្មានទឹកតែទឹកក្ដៅផង មិនសមជាកន្លែងទទួលភ្ញៀវទេ ។

ស៊ីផានរីករាយណាស់ ងក់ក្បាល :

– អូ ! អញ្ចឹងមែន ! អ្នកនាងហួ  នៅបន្ទប់ខ្ញុំមានសម្លប៉ូវប្រកបដោយរសជាតិឆ្ងាញ់ណាស់  សូមអញ្ជើញអ្នកនាងទៅញ៉ាំមួយចានសាកមើល ។

នាងក្រមុំស្រែកទាំងញ័រៗ :

– ទេ !  មិនទៅទេ !  មិនទៅទេ !

– ឆ្ងាញ់ណាស់ៗ ! សូមអ្នកនាងពិសាមួយចានមើលសិន !

ហួវ៉ាន់ដឺគំហក:

– ឯងចង់សម្លាប់ ក៏សម្លាប់ចុះ ! យើងជាសិស្សនៃក្រុមក្ដុំទឹកកកដ៏ត្រឹមត្រូវ  មិនអង្វរឯងទេ ! បើអាពោះកំណាចឯងមានគំនិតផ្ដេសផ្ដាស  យើងសុខចិត្តបោកក្បាលនឹងជញ្ជាំង មិន. . .មិនព្រមទៅបន្ទប់ឯងជាដាច់ខាត !

ស៊ីផានឆ្ងល់អនេក  សួរថា:

– ដូចជាខ្ញុំហ្នឹងចូលចិត្តសម្លាប់មនុស្សជាល្បែងអ៊ីចឹង  គួរចម្លែកមែន  នៅសុខៗម៉េចក៏ខ្ញុំសម្លាប់នាង ? នាងមិនចង់ញ៉ាំសម្លប៉ូវឈាមក៏ហើយទៅ !  អូ ! ប្រហែលជានាងចង់ញ៉ាំមាន់ ទា ឬ សាច់ត្រីទេដឹង ?

លោកឈិនកន្ទួងយើងមានរបស់អស់នេះទេ ?

ឈុនជីប្រញាប់តបភ្លាម :

– បាទ ! មាន ! មាន ! អ្នកនាងហួចង់ពិសាអ្វី  ឲ្យតែក្នុងលោកនេះមានបន្ទប់បាយយើងក៏មានដែរ !

នាងក្រមុំឆ្លើយហ៊ុះ ! តបថា:

– យើងសុខចិត្តស្លាប់មិនព្រមទទួលទានចំណីអាហារនៃក្រុមឈានល្ងង់អប្រិយទេ នាំប្រឡាក់មាត់ !

ស៊ីនផានបន្ត :

– បើដូច្នេះ អ្នកនាងហួចូលចិត្តទៅទិញពិសាខ្លួនឯងផ្សារឬ ? អ្នកនាងមានប្រាក់ទេ  បើអត់លោកឈិនមានឬទេ ? ឲ្យនាងខ្ចីទៅ !

ឈិនឈុនជីនិងហួវ៉ាន់ដឺឆ្លើយព្រមគ្នាថា:

– បាទមាន ! ចាំខ្ញុំទៅយក !

– ទេ ! ទេ ! ទោះជាស្លាប់ក៏មិនយកដែរ !

ស៊ីផានពោល :

– អូ ! ប្រហែលនាងមានប្រាក់ហើយ ! អម្បាញ់មិញលោកនាយត្រួតនិយាយថា ជើងនាងមានរបួស ខ្ញុំត្រូវទៅអញ្ជើញលោកគ្រូពេទ្យមកព្យាបាលឲ្យ តែបើនាងស្អប់ខ្ពើមក្រុមឈានល្បួងលម្ញឹង សូមនាងទៅរកគ្រូពេទ្យក្រៅចុះ ! ចេញឈាមច្រើនដូច្នេះប្រហែលមិនស្រួលទេ !

ហ្វូវាន់ដឺមិនជឿថា គេមានបំណងចិត្តប៉ងបេតនាទឹងដោះលែងនាងទេ បែរជានឹកថា គេទុកដាក់នាងជាទន្សាយជាប់ទ្រុងដែលអស់ផ្លូវនឹងរត់ដោះខ្លួនរួច ក៏កំប្លែងលេងឲ្យនាងធូរទ្រូងមួយគ្រាសិនទៅ ។

នាងស្រែកទាំងកំហឹង :

– ឯងប្រើកលល្បិចយ៉ាងណា ក៏យើងមិនចាញ់បោកឯងដែរ !

ស៊ីផានឆ្ងល់ពេកកន្លង បន្ទីវថា :

– បន្ទប់នេះ ហាក់ដូចគុកងងឹត ពិបាកសំណាក់ណាស់ អ្នកនាងហ្វូ សូមធាប់ចេញទៅក្រៅចុះ !

ហ្វូវាន់ដឺព្រឺសំដីពោរពេញដោយភាពស្មោះស្ម័គ្រ ក៏គ្រហឹម ហ៊ុះ ! សួរថា:

– ឯណាដាវ ហេតុអ្វីមិនយកឲ្យយើង ?

នាងគិតថា ប្រសិនបើមានអាវុធជាប់នឹងខ្លួន ទោះប្រយុទ្ធមិនឈ្នះ ស៊ីផាននៅពេលគេធ្វើផ្តេសផ្តាស ក៏នាងអាចធ្វើអត្តឃាតដើម្បីការពារសេចក្តីបរិសុទ្ធបានដែរ ។

ឈិនឈុងជី លបសង្កេតអាកប្បកិរិយា លោកនាយក្រុម ដោយស្ងាត់ស្ងៀម ។ ស៊ីផានពោល :

– អ្នកនាងហ្វូប្រើដាវឬ ? លោកនាយត្រួត សូមប្រគល់ដាវទៅនាងវិញចុះ បានឬទេ ?

– បាទ ! បាទ ! ដាវនៅខាងក្រៅ អ្នកនាងចេញទៅខ្ញុំនឹងយកជូនភ្លាម ។

ហ្វូវាន់ដឺនឹកថា ពុំគួរនៅទីនេះតទៅទៀតទេ គោងបេះសម្រេចចិត្តតាមកាលៈទេសៈទើបល្អប្រពៃ ។

Khmer Story Lovers

**(នៅមានត)**

ដំកល់ទុកតាមលេខ ៣០៥ ចុះថ្ងៃទី ២២ ៥ - ៧០ បោះពុម្ពលើកទី ១ ចំនួន ២០០០ ច្បាប់ .